-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា

-យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ :** ត្រូវបានគេសំរួលផ្នែកអភិវឌ្ឍន៍ របស់ការិយាល័យទី៥ ជាការិយាល័យអភិវឌ្ឍន៍យោធិន ដែលមាន ថ្នាក់ប្រហាក់ ប្រហែល ការិយាល័យ អគ្គសេនាធិការ និង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេបញ្ជាការ នាំផ្ទាល់របស់ អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ៣៣ អនក្រ
## ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេស
## អន្តរក្រសួងសំរាប់កិច្ចការរុករក និង អាជីវកម្មរ៉ែបេងកាក

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា ១ :** បង្កើតគណៈកម្មការបច្ចេកទេសអន្តរក្រសួង សំរាប់កិច្ចការរុករក និងអាជីវកម្មប្រេងកាតដែលមានសមាសភាពដូចតទៅ ÷

១_ឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហប្រធាន

២_ឯកឧត្តម **ប៉ែន សិរីវុឌ្ឍ** សហរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហប្រធាន

៣_ឯកឧត្តម **ពូ សុធីរៈ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សហប្រធាន

៤_ឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន សមាជិក

៥_ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៦_ឯកឧត្តម **លី ធុញ្ញាយស្រេង** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៧_ឯកឧត្តម **ក្រាំ អ៊ីចភីក** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៨_ឯកឧត្តម **អ៊ុច គីមអន** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩_ឯកឧត្តម **ហេង វឌ្ឍមិនឆាក** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ១ សមាជិក

១០_លោកជំទាវ **ហូ ណាន** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

១១_ឯកឧត្តម **ប៊ិន អ៊ុយ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១២_ឯកឧត្តម **ម៉ៃ សំអឿន** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសមាជិក

១៣_ឯកឧត្តម **ពៅ ប៊ុនឋិន** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល សមាជិក និងជាលេខាធិការអចិន្ត្រៃយ៍

**មាត្រា ២ :** គណៈកម្មការបច្ចេកទេសអន្តរក្រសួងសំរាប់កិច្ចការរុករក និង អាជីវកម្មប្រេងកាតមានតួនាទី សំរបសំរួលនិងសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធ និងខេត្តក្រុង ជាពិសេសជាមួយក្រុម ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងគ្រប់គ្រងបរិដ្ឋាន ដើម្បីអនុវត្តអោយស៊ីសង្វាក់គ្នា ប្រទាក់ក្រឡា និងមានសមត្ថភាព ។

**មាត្រា ៣ :** គណៈកម្មការបច្ចេកទេសអន្តរក្រសួងសំរាប់កិច្ចការរុករក និងអាជីវកម្មប្រេងកាតមានភារកិច្ច ÷

_សិក្សាស្រាវជ្រាវដើម្បីរៀបចំច្បាប់ប្រេងកាត ( PETROLEUM LAW ) នៃព្រះរាជាណាចក្រកម្ពុជា

- ពិនិត្យពិចារណាលើរាល់គំរោងកិច្ចព្រមព្រៀងរបស់ក្រុមហ៊ុននានាដែលបានស្នើធ្វើវិនិយោគការរុករក និងអាជីវកម្មប្រេងកាត
- សំរបសំរួល និងសហការយ៉ាងជិតស្និទ្ធជាមួយបណ្តា ស្ថាប័នពាក់ព័ន្ធនិងក្រុមហ៊ុនវិនិយោគសំដៅលើកវិធានការការងារ និង បង្កលក្ខណៈងាយស្រួលធានាប្រសិទ្ធភាពលើការរុករក និងអាជីវកម្មប្រេងកាត
- ជំរុញ និង តាមដានការអនុវត្ត ន័យ័ក្ខការណ៍ និង គោលការណ៍របស់រាជរដ្ឋាភិបាល
- ចុះហត្ថលេខាលើឯកសារជាផ្លូវការមួយចំនួន ក្រោយពីមានការសំរេចពីប្រមុខរាជរដ្ឋាភិបាល ។
- ធ្វើរបាយការណ៍អោយបានទៀងទាត់ ជូនរាជរដ្ឋាភិបាល អំពីសកម្មភាព និងលទ្ធភាពដែលសំរេចបាន ។

**មាត្រា ៤ :** សមាជិកគណៈកម្មការត្រូវចូលប្រជុំ ធ្វើការងារតាមការអញ្ជើញ និងណែនាំរបស់សហប្រធាន ។

**មាត្រា ៥ :** គណៈកម្មការបច្ចេកទេសអន្តរក្រសួង សំរាប់កិច្ចការរុករក និង អាជីវកម្មប្រេងកាតស្ថិតនៅក្រោមការទទួលខុសត្រូវរបស់សហប្រធាន ។

**មាត្រា ៦ :** គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយប្រចាំនៅក្រសួងឧស្សាហកម្ម និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួង ឧស្សាហកម្ម ។

**មាត្រា ៧ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និងឯកឧត្តមលោកជំទាវដែលមានឈ្មោះក្នុងមាត្រា ១ ព្រមទាំងបណ្តាក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *